# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក-អ.ជ.ស.ជ

ភាគីដាក់ឯកសារ: ក្រុមមេធាវីការពារក្តីលោក នួន ជា

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១២

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 31-Jan-2012, 13:52
CMS/CFO: Sann Rada

## ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ សាធារណៈ/Public

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

## បញ្ជីឯកសារដែលត្រូវដាក់នៅដំណាក់កាលដំបូងនៃការជំនុំជម្រះ នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង

---

ដាក់ដោយ៖

**ក្រុមមេធាវីការពារក្តី នួន ជា**

សុន អរុណ

Michiel PESTMAN
Victor KOPPE
Andrew IANUZZI
Jasper PAUW

ព្រុំ ផល្លា

Mojan SAMADI
Tomas HAMILTON

ផ្ញើជូន៖

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Andrew CAYLEY

**ក្រុមមេធាវីការពារក្តីទាំងអស់**

# I. សេចក្តីផ្តើម

១. មេធាវីការពារក្តីជនជាប់ចោទ នួន ជា ("ក្រុមមេធាវីការពារក្តី") សូមដាក់បញ្ជីឯកសារដំបូងរបស់ខ្លួនដែលត្រូវដាក់នៅដំណាក់កាលដំបូងនៃការជំនុំជម្រះករណី ០០២ នៅចំពោះមុខ អង្គជំនុំជម្រះសាលាដំបូង។ ឯកសារទាំងនេះត្រូវបានចងក្រងជាបញ្ជីនៅក្នុងឧបសម្ព័ន្ធ ដែលភ្ជាប់ជាមួយ ព្រមជាមួយព័ត៌មានបន្ថែមទាក់ទងនឹងទីតាំង ខ្លឹមសារ ប្រភព និងភាពពាក់ព័ន្ធរបស់ឯកសារទាំងនេះ។ សំណៅនៃឯកសារទាំងនេះ ដែលមិនទាន់ដាក់បញ្ចូលក្នុងសំណុំរឿង ត្រូវបានដាក់ភ្ជាប់មកជាមួយ។ ក្រុមមេធាវីការក្តីប្រកាន់ជំហរថា សារណានេះ (និងសម្ភារៈភ្ជាប់ជាមួយ) ត្រូវតែចាត់ថ្នាក់ជាសារណៈ។ ទោះជាក្នុងករណីណាក៏ដោយ ក្រុមមេធាវីការពារក្តីចាត់ទុកសារណានេះ និងសម្ភារៈដែលភ្ជាប់ជាមួយថា ជាសារធារណៈ ។

# II. សារណា

## ក. ឯកសារអាចទទួលយក

២. អនុលោមតាមក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា (កនព)[1] វិធានផ្ទៃក្នុង អវតក (វិធានផ្ទៃក្នុង)[2] និងយុត្តិសាស្ត្រអន្តរជាតិពាក់ព័ន្ធ[3] ឯកសារដែលក្រុមមេធាវីការពារក្តីមានបំណងដាក់នេះ ឆ្លើយតបទៅនឹងលក្ខខណ្ឌបឋមនៃភាពអាចទទួលយកបាននៃភស្តុតាង [4]។

### *១. ឯកសារជាប់ពាក់ព័ន្ធ*

---

[1] សូមមើលកថាខណ្ឌ ៥ ខាងក្រោម ។

[2] វិធាន ៨៧(១) ចែងនៅផ្នែកពាក់ព័ន្ធថា៖ "លើកលែងតែមានបទប្បញ្ញត្តិផ្សេងក្នុងវិធានផ្ទៃក្នុងនេះ រាល់ភស្តុតាងទាំងអស់ត្រូវតែទទួលយក" ។

[3] ឧទាហរណ៍ សូមមើលឯកសារ **E-1/27.1**, "ប្រតិចារិកនៃសវនាការថ្ងៃទី១៦ ខែមករា ឆ្នាំ២០១២ (ថ្ងៃសវនាការទី១៥) ERN 00770067–00770197, pp 31:16–32:5 ។

[4] សូមមើលពង្រាង "កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី" ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១២ (សវនាការលើកទី២២) មិនទាន់មាន ERN ទំព័រ ៨៦:៩-២២។

៣. ដូចដែលបានលើកឡើងនៅសវនាការថ្មីៗនេះទៅលើភស្តុតាងជាឯកសារ ហើយបើពិចារណាពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងបំបែកកិច្ចដំណើរការនីតិវិធីក្នុងករណី ០០២ "ចំណុចស្នូល" នៃដំណើរការនីតិវិធីនេះគឺការចោទប្រកាន់អំពីការចូលរួមរបស់ នួន ជា នៅក្នុងការផ្លាស់ទីលំនៅប្រជាជននៅដំណាក់កាលទី១ និងដំណាក់កាលទី២ស្អីគេនោះ"[5]។ វាច្បាស់ណាស់ថាចំណុចនេះគ្របដណ្តប់លើការជំរុញទឹកចិត្តខុសៗគ្នាមកលើជនជាប់ចោទពាក់ព័ន្ធជាមួយការពាក់ព័ន្ធរបស់គាត់នៅក្នុងសកម្មភាពនេះ ព្រមជាមួយការស្លាប់ប្រជាជនបណ្តាលមកពីការផ្លាស់ទីលំនៅដោយបង្ខំនេះ។ បន្ថែមពីលើនេះ ដូចដែលក្រុមមេធាវីការពារក្តីបានលើកឡើងជាញឹកញាប់ "ការជ្រៀតជ្រែកខាងនយោបាយនៅចំណុចណាមួយនៃដំណើរការនីតិវិធី គឺជាប់ពាក់ព័ន្ធជានិច្ច មិនថាជាប្រធានបទអ្វីនោះទេ"[6]។ ដូចដែលមានចែងយ៉ាងលំអិតនៅក្នុងឧបសម្ព័ន្ធភ្ជាប់ជាមួយ សារណានេះ ឯកសារនីមួយៗគឺទាក់ទងនឹងបញ្ហាជាក់លាក់មួយឬច្រើន[7]។

---

[5] ឯកសារ **E-124** ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីអនុលោមតាមវិធាន ៨៩ ស្ទួន ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១១ ERN 00743502–00743502 ("ដីកាសម្រេចបំបែកកិច្ចដំណើរនីតិវិធី") នៅកថាខណ្ឌ៥(ក) ។ សូមមើលផងដែរពង្រាងប្រតិចារិតសវនាការ"ចុះថ្ងៃទី១៩ ខែមករាឆ្នាំ ២០១២ (សវនាការថ្ងៃទី១៨) លេខ ERN មិនទាន់កំណត់នៅឡើយ ។

[6] ឯកសារ **E-1/23.1** ប្រតិចារិតសវនាការ ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ ២០១១ (សវនាការថ្ងៃទី១១) ERN 00762459–00762563, p 101:10–11.។ សូមមើលផងដែរឯកសារ **E-116/1**, "បណ្តឹងសារទុក្ខជាបន្ទាន់ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងនឹងភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ" ចុះថ្ងៃទី ១០ ខែតុលា ឆ្នាំ២០១១ ERN 00746636–00746658 ។

[7] កំណត់សំគាល់៖ ក្រុមមេធាវីការពារក្តីបានជូនដំណឹងអង្គជំនុំជម្រះសាលាដំបូង និងភាគីរួចមកហើយពីចេតនារបស់ខ្លួនក្នុងការដាក់ឯកសារជាភស្តុតាង ដែលក្នុងចំណោមបញ្ហាដទៃទៀត ទាក់ទងនឹង (i) ប្រធានបទជាក់លាក់ដែលត្រូវបានកំណត់អត្តសញ្ញាណកម្មនៅក្នុងសំណើរបស់ក្រុមមេធាវីការពារក្តី សុំឲ្យបំពេញកិច្ចស៊ើបសួរ, (ii) ដំណាក់កាលពីរដំបូងនៃការផ្លាស់ទីលំនៅប្រជាជន រួមទាំងការអាចមានសកម្មព្រហ្មទណ្ឌរបស់បុគ្គលទាំងឡាយដែលមិនបានចូលខ្លួននៅចំពោះមុខការិយាល័យសហចៅក្រមស៊ើបអង្កេត តាមដីកាកោះហៅស្របច្បាប់, (iii) ចំនួនអ្នកស្លាប់សរុប រួមមានជនទាំងឡាយដែលស្លាប់ក្នុងការអនុវត្តផែនការ ក-៥ ស្អីគេនោះ និង(iv) ការជ្រៀតជ្រែកខាងនយោបាយនៅក្នុងកិច្ចការរបស់ អវតក ។ សូមមើលឯកសារ No **E-9/26** "ការជូនដំណឹងអំពីការចូលរួមជាមួយសារណាបឋមរបស់លោក អៀង សារី ទាក់ទងនឹងឯកសារដែលត្រូវលើកមកសំអាងនៅសវនាការ និងសារណាបន្ថែមទាក់ទងនឹងឯកសារថ្មី" ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១១ ERN 00665543–00665546, នៅកថាខណ្ឌទី ៥ ។ ឯកសារ **E-131/1/9**, "ការជំទាស់ ការអង្កេត និងការជូនដំណឹងអំពី

### *២. ឯកសារអាចជឿទុកចិត្តបាន*

៤. ដោយប្រកាន់យកវិធីសាស្ត្រដែលបង្កើតឡើងដោយការិយាល័យសហព្រះរាជអាជ្ញា(“កសព”) ទាក់ទងនឹងសញ្ញាណបឋមនៃភាពអាចជឿទុកចិត្តរបស់ឯកសារដែល កសព បានដាក់[8] ក្រុមមេធាវីការពារក្តីស្នើថា “ភិនភាគខាងក្នុង” និង“លក្ខណៈខាងក្រៅ” នៃឯកសារដែលដាក់ដោយមេធាវីការពារក្តី បញ្ជាក់ថាឯកសារនីមួយៗ គឺអាចជឿទុកចិត្តបានជាបឋម។ ឯកសារ២១ នៃឯកសារដែលបានដាក់ជាផ្នែកនៃសំណុំរឿងរួចមកហើយ ហើយសឹងតែគ្រប់ឯកសារទាំងអស់ត្រូវបានប្រើប្រាស់ដោយភាគីមួយ ឬភាគីច្រើននៅក្នុងដំណើរការនីតិវិធី។ លើកលែងតែឯកសារពីរចុងក្រោយ ឯកសារដែលនៅសល់អាចរកបានជាសារណៈ។ មានឯកសារមួយចំនួនមានរក្សានៅបណ្ណសារដ្ឋានរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា (‘DC-Cam’), ហើយអ្នកនិពន្ធនៃឯកសារ ទាំងនេះជាមនុស្សមានឈ្មោះបោះសម្លេង និងអាចមកផ្តល់សក្ខីកម្ម (ធានាអះអាងលើស្នាដៃនិពន្ធរបស់ពួកគេ)[9]។ ជាសង្ខេប នៅដំណាក់កាលនេះពុំមានអ្វីដែលបង្ហាញថាឯកសារណាមួយដែលបានដាក់រួចមកហើយ មិនមានគោលបំណងអ្វីនោះទេ។

### *៣. ពុំមានការតម្រូវពីការជូនដំណឹងជាមុនដោយច្បាប់កម្ពុជាឡើយ*

៥. ដូចដែលបានលើកឡើងជាច្រើនដងរួចមកហើយ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាមិនបានចែងពីតម្រូវការឲ្យមានការជូនដំណឹងជាមុន ទាក់ទងនឹងសិទ្ធិបង្ហាញភស្តុតាងជាឯកសារនៅសវនាការ[10]។ មាត្រា ៣៣៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាចែងថា “រហូតដល់ការបិទកិច្ចពិភាក្សា

---

ឯកសារផ្សេងៗដែលត្រូវដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១១ ERN 00752669–00752684 នៅកថាខណ្ឌទី ៣២ ដល់ ៣៤ ។

[8] សូមមើលឯកសារ E-158 “សារណារបស់សហព្រះរាជអាជ្ញា តាមវិធាន ៩២ ទាក់ទងនឹងសញ្ញាណនៃភាពអាចជឿទុកចិត្តបាននៃឯកសារចំនួន ៩៧៨ ដែលត្រូវបានចងក្រងជាបញ្ជីឯកសារពាក់ព័ន្ធនឹងសាក្សី និងអ្នកជំនាញដែលអាចត្រូវបានកោះហៅនៅដំណាក់កាលបីសប្តាហ៍ដំបូងនៃការជំនុំជម្រះ” ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១១ ERN 00763101–00763158 នៅកថាខណ្ឌទី ៣ ។

[9] សូមមើលកថាខណ្ឌទី ៨ ខាងក្រោម ។

[10] សូមមើលឯកសារ No **E-1/27.1**, ឧទាហរណ៍ សូមមើលឯកសារ **E-1/27.1**, “ប្រតិចារិតនៃសវនាការថ្ងៃទី១៦ ខែមករា ឆ្នាំ២០១២ (ថ្ងៃសវនាការទី១៥) ERN 00770067–00770197, pp 31:16–14 ។

ដេញដោល ជនជាប់ចោទ [...] អាច [...] អាចដាក់ឯកសារ និងភស្តុតាងទាំងអស់ ដែលមានប្រយោជន៍ដល់ការសម្តែងឱ្យឃើញការពិត[11]។ បន្ទាប់ពីទទួលបានព័ត៌មាននេះ និងការជឿជាក់ បទប្បញ្ញត្តិនេះមិនទាន់ត្រូវបានបំពេញ ដាក់កម្រិត ឬ កែប្រែដោយច្បាប់ និង/ តុលាការកម្ពុជានៅឡើយទេ។

៦. តាមរយៈការបកស្រាយវិធាន ៨៧(៣) និង ៨៧(៤) អង្គជំនុំជម្រះសាលាដំបូងបានប៉ុនប៉ងដាក់លក្ខខណ្ឌតម្រូវយ៉ាងតឹងរឹងបំផុតលើការទទួលយក និងការប្រើប្រាស់ឯកសារដែលមិនបានដាក់ស្របតាមកាលបរិច្ឆេទលើកមុន[12]។ ក្រៅពីការខកខានរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការផ្តល់ការគាំទ្រផ្នែកច្បាប់សម្រាប់គោលជំហរបំផ្លើសរបស់ខ្លួន ការដាក់ពេលវេលាកំណត់ និងរនាំងសប្បនិម្មិតនេះ គឺមិនល្អនោះទេ ដែលផ្ទុយទៅនឹងខ្លឹមសារ និងស្មារតីមាត្រា ៣៣៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា។ វាហាក់ដូចជាបង្កើតឡើងដើម្បីដាក់ទណ្ឌកម្មដល់មេធាវីការពារក្តីចំពោះភាពមិនស៊ីចង្វាក់គ្នាជាមួយដំណើរការនីតិវិធីអនុលោមតាមនីតិវិធី និងការអនុវត្តរបស់កម្ពុជាដែលនៅជាធរមាន[13]។ ដូចដែលមេធាវីការពារក្តីបានលើកឡើងហើយ

---

[11] ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មាត្រា ៣៣៤ (បញ្ជាក់បន្ថែម) ។

[12] ឯកសារ **E-131/1**, អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពី "បញ្ជីសាក្សីសម្រាប់ការជំនុំជម្រះនៅដំណាក់ដំបូង កាលបរិច្ឆេទកំណត់សម្រាប់ការជំទាស់ភាពអាចទទួលយកបាននៃឯកសារ និងវត្ថុតាង និងចម្លើយតបទៅនឹងសំណើ E-109/5, ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១១ ERN 00747683–00747686, (អនុស្សរណៈឯកសារ) p 4 ("ឯកសារដែលមិនបានដាក់តាមពេលវេលាកំណត់នាពេលកន្លង ត្រូវតែឆ្លើយតបទៅនឹងលក្ខខណ្ឌ័តឹងរឹងបំផុត ដោយការបង្ហាញថាឯកសារទាំងនោះ មិនអាចរកបានតាមកាលបរិច្ឆេទកំណត់បានទេ ទោះបីជាមានការយកចិត្តទុកដាក់ស្វះស្វែងរកក៏ដោយ និងការបង្ហាញថាការទទួលយកឯកសារដែលមិនដាក់តាមពេលវេលាកំណត់នេះ គឺជាការចាំបាច់ដើម្បីផលប្រយោជន៍យុត្តធម៌ ។ ការកំណត់លក្ខខណ្ឌ័តឹងរឹងទាំងនេះបង្ហាញយ៉ាងច្បាស់ថា សំណើសុំដាក់ឯកសារ មិនទំនងជានឹងទទួលបានជោគជ័យឡើយ ។

[13] ឯកសារ **E-131/1/9**, "ការជំទាស់ ការកត់សម្គាល់ និងការជូនដំណឹងអំពីឯកសារផ្សេងៗដែលត្រូវដាក់នៅចំពោះមុខអង្គជំនុជម្រះសាលាដំបូង ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១១ ERN 00752669–00752684 នៅកថាខណ្ឌទី២៥ ។ ( ពាក់ព័ន្ធទៅនឹងគោលជំហររបស់អង្គជំនុំជម្រះ ទាក់ទងទៅនឹងការទទួលស្គាល់ឯកសារថ្មីៗនៅពេលសវនាការ" វាមានការពិបាកយល់ដែលថា ចៅក្រមក្នុងសវនាការតាមច្បាប់ស៊ីវិល គួរតែមានបំណងបញ្ជាក់ឱ្យច្បាស់ពីវិធីសាស្ត្របដិសេធអ្វីដែលអាចជាភស្តុតាង ជាពិសេសមុនពេលកិច្ចដំណើរការនីតិវិធីបានចាប់ផ្តើម ។ តួនាទីដំបូងរបស់អង្គជំនុំជម្រះនេះ ក្រៅពីគ្រាន់តែសម្រះសម្រួលវិវាទដែលមានភស្តុតាង ក្នុងចំណោមភាគីផ្សេងៗ គឺត្រូវរកឱ្យឃើញនូវការពិតជាវិជ្ជមានពាក់ព័ន្ធនឹងការចោទ

ថា "តួនាទីចម្បងរបស់អង្គជំនុំជម្រះនេះគឺត្រូវតែសម្របសម្រួលនូវរវាងភាគីទាំងអស់ គឺថា [...] ដើម្បីស្វែងរកឲ្យឃើញនូវការពិត"[14]។

៧. ក្នុងករណីណាក៏ដោយ ផ្នែកតូចមួយនៃឯកសារដែលបានដាក់ជូននេះ អាចត្រូវបានគេចាត់ទុកថាជា"ឯកសារថ្មី"[15] ដូចដែលបានគូសបញ្ជាក់រួចមកហើយ ឯកសារទាំងនេះភាគច្រើន គឺមាននៅក្នុងសំណុំ រឿងរួចហើយ និង/ឬត្រូវបានយោងក្នុងសារណារបស់ភាគីផ្សេងៗគ្នា។ បន្ថែមលើនេះទៅទៀត នៅក្នុងបញ្ជីឯកសារដំបូងនេះ មេធាវីការពារក្តីបានផ្តល់នូវ "សេចក្តីសន្និដ្ឋានដែលមានសំអាងហេតុ" ទាក់ទងនឹងបញ្ហាថាតើហេតុអ្វីបានជាឯកសារទាំងអស់គួរតែត្រូវបានទទួលយក[16]។ ឯកសារសំខាន់ទាំងនោះពាក់ព័ន្ធយ៉ាងច្បាស់ក្នុងសំណុំរឿង 00២/0១ ហើយវាមានប្រយោជន៍ដល់ការសំដែងឲ្យឃើញការពិត អនុលោមតាមមាត្រា ៣៣៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា។ ជាងនេះទៅទៀត ដោយសារតែចំនួនឯកសារត្រូវបានកម្រិតយ៉ាងតឹងរឹង គ្មានភាគីណាមួយអាចអះអាងពីភាពលម្អៀង ដែលកើតចេញមកពីការទទួលយកឯកសារនៅក្នុងដំណាក់កាលនេះបានឡើយ។ ក្នុងកម្រិតមួយដែលឯកសារណាមួយ ដែលក្នុងពេលនេះមិនទាន់មានជាបីភាសាផ្លូវការរបស់ អវតក មេធាវីការពារក្តីបានដាក់សំណើពិសេសសុំការបកប្រែទៅកាន់អង្គភាពបកប្រែនៅ អវតក។

---

ប្រកាន់នានា ដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានកែប្រែ។ ចៅក្រមទាំងឡាយហាក់បីដូចមានសិទ្ធិមុនគេរួចទៅហើយក្នុងការទទួកយកភស្តុតាងដែលអាចមាន និងមិនត្រូវមើលឃើញមកទល់នឹងពេលនេះ តាមរយៈការដាក់បទដ្ឋានតឹងរឹងដែមមិនចាំបាច់មួយ (ដោយគ្មានមូលដ្ឋានផ្លូវច្បាប់។ រឹតតែអាក្រក់ទៀត នោះវាហាក់ដូចជាចៅក្រមទាំងនោះបានធ្វើបែបនេះដោយយល់ឃើញថាជាការស្តីបន្ទោស មេធាវីការពារក្តីចំពោះការអះអាង និងរក្សាគោលជំហររបស់ខ្លួនពាក់ព័ន្ធទៅនឹងនីតិវិធីកម្ពុជាជាធរមាន ។

[14] ឯកសារលេខ **E-1/27.1** "កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី" ថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០១២ (សវនាការលើកទី ១៥) ERN 00770067–00770197, ទំព័រ ៣៩: ១-៣។

[15] សូមមើល អនុស្សរណៈឯកសារ ទំព័រ៤។ *សម្គាល់* ឯកសារជាក់លាក់មិនទាន់មានក្នុងសំណុំរឿង ជាពិសេសឯកសារដែលទាក់ទងនិង "ផែនការ ក-៥) មេធាវីការពារក្តីទើបតែទទួលបានក្នុងពេលថ្មីៗនេះទេ គឺមិនអាចត្រូវបានដាក់ក្នុងពេលខាងដើម។

[16] *សូមមើល*វិធាន ៨៧(៤)។

### *ខ. ឯកសារនេះនឹងត្រូវធ្វើឲ្យមានយថាភាពបន្ថែមទៀតតាមរយៈសាក្សី*

៨. មេធាវីការពារក្តីមិនមានសំណៅរឹងនៃឯកសារដែលបានដាក់ជូននេះទេ។ ដូចដែលបានគូសបញ្ជាក់ពីខាងលើ សំណៅរឹងដែលមាននៅក្នុងសំណុំរឿង និងដែលបានភ្ជាប់មកជាមួយនេះ ពិតជាមានសញ្ញាណបញ្ជាក់ពីភាពពាក់ព័ន្ធ និងភាពអាចជឿជាក់បានល្មមគ្រប់គ្រាន់ដើម្បីឲ្យអង្គជំនុំជម្រះទទួលយកនៅក្នុងដំណើរការនីតិវិធីនៅដំណាក់កាលនេះ[17]។ ជាងនេះទៅទៀត ដោយសារតែឯកសារទាំងនេះ ពាក់ព័ន្ធទៅនឹងបញ្ហាសារតារ និងបរិបទ (ដែលផ្ទុយទៅនឹងទង្វើ និងការប្រព្រឹត្តរបស់ជនជាប់ចោទ) វិធីសាស្ត្រដែលមានលក្ខណៈអាចបទបែនជាងមុនចំពោះការទទួលយកឯកសារទាំងនោះ គួរតែយកមកអនុវត្ត[18]។ ទាក់ទងនឹងឯកសារនីមួយៗដែលបានដាក់ជូនកាលពីមុន មេធាវីការពារក្តីបានស្នើសុំឲ្យសាក្សីជាក់លាក់មួយចំនួនបង្ហាញខ្លួន ដែលតាមរយៈការបង្ហាញខ្លួននេះបញ្ហាអំពីយថាភាព (ក៏ដូចជាបញ្ហាទាក់ទងនឹងខ្លឹមសារនៃឯកសារ) អាចត្រូវបានដោះស្រាយ។ ប៉ុន្តែអង្គជំនុំជម្រះសាលាដំបូង មិនទាន់ដោះស្រាយបញ្ហានេះឲ្យបានជាក់លាក់នៅឡើយទេ។ ក្នុងករណីណាក៏ដោយ មេធាវីការពារក្តីមានបំណងធ្វើយថាភាពលើឯកសារទាំងនេះ និងធ្វើការផ្ទៀងផ្ទាត់លើខ្លឹមសាររបស់វាបន្ថែមទៀត ដោយដាក់ឯកសារទាំងនោះទៅកាន់សាក្សីផ្សេងៗគ្នា ដែលគ្រោងនឹងបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះ រួចជាស្រេចហើយ។ មេធាវីការពារក្តីនឹងស្នើឲ្យកោះហៅបុគ្គលមួយចំនួនបន្ថែមទៀតពីក្នុងបញ្ជីសាក្សីរបស់ខ្លួនដែលបានដាក់រួចមកហើយ (រួមមាន ហ៊ុន សែន និងអ្នកតំណាងរបស់រាជរដ្ឋាភិបាលដទៃទៀត) ដែលមិនទាន់ត្រូវបានរៀបចំដោយអង្គជំនុំជម្រះនៅឡើយ។

### គ. ឯកសារបន្ថែមទៀត នឹងត្រូវដាក់ជូនឲ្យបានទាន់ពេលវេលា

[17] *សូមមើល* ឧទាហរណ៍ ឯកសារ **E-1/27.1,** “ប្រតិចារិកនៃដំណើរការនីតិវិធីជំនុំជម្រះក្តី”, ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១២ (ថ្ងៃទីសវនាការ ១៥), ERN 00770067–00770197, pp 33:21–35:2។

[18] សូមមើលកថាខណ្ឌទី៣ ដល់ទី៤, ដូចដើងទំព័រខាងលើ។

៩. អនុលោមតាមនីតិវិធី និងការអនុវត្តជាធរមានរបស់កម្ពុជា តទៅនេះលោក នួន ជា សូមរក្សាសិទ្ធិយោងទៅឯកសារទាំងអស់ ដែលគាត់ចាត់ទុកថាមានប្រយោជន៍ក្នុងការស្វែងរកការពិតនៅគ្រប់ពេលវេលាទាំងអស់ "រហូតដល់ចុងបញ្ចប់នៃសវនាការ"[19]។

## III. **សេចក្ដីសន្និដ្ឋាន**

១០. អាស្រ័យលើហេតុផលដែលបានគូសបញ្ជាក់ខាងលើ និងកាលពីមុនមក មេធាវីការពារក្ដីសូមស្នើឲ្យអង្គជំនុំជម្រះសាលាដំបូងទទួលយកឯកសារដែលបានយោងនៅក្នុងឧបសម្ព័ន្ធដែលភ្ជាប់មកជាមួយជាភស្តុតាងក្នុងសំណុំរឿង ០០២/០១។ មេធាវីការពារក្ដីទទួលស្គាល់ថាបញ្ហាទម្ងន់ ឬតម្លៃអាចជឿជាក់បាននៃឯកសារថាមានទំហំប៉ុនណានោះ គឺត្រូវតែកំណត់នៅចុងបញ្ចប់នៃដំណើរការនីតិវិធីព្រមជាមួយនឹងភស្តុតាងដទៃទៀតដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ។

**សហមេធាវីការពារក្ដីលោក នួន ជា**





**សុន អរុណ**

Michel PESTMAN & Victor KOPPE

[19] កសព មាត្រា ៣៣៤។ *សម្គាល់* នេះដោយរាប់បញ្ចូលទាំងឯកសារដែលទាក់ទងនឹងការសួរដេញដោលសាក្សីដែលកោះហៅដោយអង្គជំនុំជម្រះ និង ឬដោយភាគីផ្សេងទៀត។ សូមមើល សារអេឡិចត្រូនិចពីមន្ត្រីជាន់ខ្ពស់ផ្នែកច្បាប់ កម្មវត្ថុ "ឆ្លើយតបនឹងបញ្ហាដែលលើកឡើងក្នុងអំឡុងកិច្ចប្រជុំរៀបចំសវនាការ" នៅថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០១១។ ("ពុំមានកាតព្វកិច្ចណាមួយដើម្បីដាក់ឯកសារដែលចាត់ទុកថាទាក់ទងនឹងសាក្សីដែលបានកោះហៅដោយភាគីនោះទេ")។